២សាំយូអែល៦:១-២៣

# ជំពូក ៦

*ចំណងជើង ស្តេចដាវីឌធ្វើត្រូវក្នុងផ្លូវខុស*

ជំពូក៦ សម្តែងពីសកម្មភាពដែលក្សត្រដាវីឌធ្វើត្រូវតែក្នុងផ្លូវខុស។ លោកមានចិត្តចង់នាំហិបសញ្ញារបស់ព្រះយេហូវ៉ាចូលមកក្នុងទីក្រុងយេរូសាឡិម។ នៅពេលដែលលោកទៅដង្ហែរយកហិបសញ្ញានោះមក លោកមិនអោយសង្ឃសែងហិបតាមក្រឹត្យវិន័យរបស់ព្រះជាម្ចាស់បង្គាប់មកទេ លោកបែរជាដាក់ហិបនោះលើរទេះទៅវិញ។ ឯច្បាប់ដែលចែងថា ហិបត្រូវសង្ឃសែងនោះ មានរៀបរាប់ក្នុងគម្ពីរជនគណនា៧:៩។ លោកអ៊ុសាយកដៃទៅប៉ះហិបសញ្ញា បណ្តាលអោយលោកស្លាប់នៅពេលនោះ។ បន្ទាប់ពីពេលនោះមក ស្តេចដាវីឌធ្វើតាមព្រះបន្ទូលរបស់ព្រះអង្គវិញ។ ដូច្នេះ ហិបសញ្ញាក៏បាននាំចូលទៅទីក្រុងយេរូសាឡិមដោយសុវត្ថិភាព។ ចំណែកនាងមីកាលដែលជាជាយារបស់ក្សត្រដាវីឌ មិនសប្បាយចិត្តដោយឃើញក្សត្រដាវីឌរាំថ្វាយព្រះ ក្នុងពេលដែលទ្រង់នាំហិបសញ្ញាចូលមកក្នុងទីក្រុង។

យើងអាចអោយចំណងជើងជំពូក៦ថា "ក្សត្រដាវីឌធ្វើត្រូវក្នុងផ្លូវខុស"។ កិរិយាប្រព្រឹត្តបែបនេះ ខ្មែរយើងហៅថា "ចូលស្ទឹងតាមបត់"។ ស្តេចដាវីឌមិនមែនប្រើវិធីនេះ នៅក្នុងជីវិតរបស់លោកទេ។ លោកប្រើទ្រឹស្តីនេះ នៅពេលដែលលោក

នាំហិបសញ្ញារបស់ព្រះជាម្ចាស់ចូលមកទីក្រុងយេរូសាឡិមតែប៉ុណ្ណោះ។ ធ្វើដូចម្តេចក៏ធ្វើទៅ អោយតែបានហិបសញ្ញាចូលមកដល់ទីក្រុង។ សេចក្តីដែលមានកត់ត្រាទុកនៅក្នុងបទគម្ពីរត្រង់ចំណុចនេះ បង្ហើបអោយយើងដឹងថា នៅក្នុងទំព័រជីវិតរបស់ក្សត្រដាវីឌ លោកប្រព្រឹត្តខុសយ៉ាងដូច្នោះដែរ។

នៅក្នុងជីវិតក្សត្រដាវីឌ មានព្រឹត្តិការណ៍ធំៗកើតឡើងច្រើនណាស់។ ឯព្រឹត្តិការណ៍ដែលធំជាងគេបង្អស់ មានចំនួនពីរយ៉ាងគឺ ទីមួយថ្ងៃដែលស្តេចដាវីឌដង្ហែរហិបសញ្ញារបស់ព្រះជាម្ចាស់ចូលនៅក្នុងទីក្រុងយេរូសាឡិម ដូចមានសម្តែងនៅក្នុងជំពូក៦ស្រាប់។ ឯព្រឹត្តិការណ៍មួយទៀត គឺពេលដែលលោកមានចិត្តចង់សង់ព្រះវិហារថ្វាយព្រះជាម្ចាស់។ រឿងនោះមានសម្តែងនៅក្នុងជំពូក៧។

ហិបសញ្ញាសម្តែងអំពីវត្តមានរបស់ព្រះជាម្ចាស់ គង់នៅជាមួយនឹងរាស្ត្ររបស់ទ្រង់។ ហិបសញ្ញាត្រូវស្ថិតនៅក្នុងទីបរិសុទ្ធបំផុត ក្នុងបរិវេណនៃរោងឧបោសថ។ នៅក្នុងទីបរិសុទ្ធបំផុត មានគ្រឿងសក្ការៈបីយ៉ាងគឺ ជើងចង្កៀងមាស អាសនាមាស ហើយនិងតុសម្រាប់តម្កល់នំបុ័ងតាំងទុក។ គ្រឿងសក្ការៈទាំងបីនេះ ជានិមិត្តរូបនៃអង្គព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់ត្រូវទទួលការថ្វាយបង្គំពីមនុស្សលោក ដែលកើតមកក្នុងលោកីយ៍នេះ។ នៅក្នុងទីបរិសុទ្ធបំផុត មានហិបសញ្ញារបស់ព្រះអម្ចាស់តម្កល់នៅទីនោះ។ ឯហិបសញ្ញានោះទៀតសោត គឺជានិមិត្តរូបនៃបល្ល័ង្កព្រះគុណ។ នៅទីនោះព្រះជាម្ចាស់យាងមកជួបជាមួយនឹងរាស្ត្ររបស់ទ្រង់។ ហិបសញ្ញាជារូបភាពនៃអង្គព្រះយេស៊ូវគ្រីស្ទ នៅក្នុងព្រះគម្ពីរសញ្ញាចាស់។

ហិបនេះជារូបភាពនៃអង្គព្រះយេស៊ូវគ្រីស្ទ មិនមែនជាផ្នែកខាងអត្ថានុរូបទេ គឺមានខ្លឹមសារខាងបដិរូបវិញ។ ហិបសញ្ញាធ្វើពីឈើធម្មតា។ ឯទំហំ គឺត្រូវធ្វើត្រឹមត្រូវតាមខ្នាតដែលព្រះជាម្ចាស់ទ្រង់ប្រទានអោយ។ ឈើត្រូវស្រោបដោយមាស ពីខាងក្នុងនិងមាសពីខាងក្រៅ។ ព្រះជាម្ចាស់ប្រទានអំណោយទានដល់លោកបេសាលៀល ដើម្បីអាចឆ្លាក់ធ្វើហិបសញ្ញាសម្រាប់ព្រះជាម្ចាស់។ សាសន៍អ៊ីស្រាអែលខ្លះយល់ថា ហិបសញ្ញាជាវត្ថុស័ក្តសិទ្ធិ។ តាមពិតទៅហិបសញ្ញាមិនមែនជាវត្ថុស័ក្តសិទ្ធិអ្វីទេ គ្រាន់តែជានិមិត្តរូបពីខ្លឹមសារនៃអង្គព្រះយេស៊ូវគ្រីស្ទតែប៉ុណ្ណោះ។ ហិបសញ្ញាជានិមិត្តរូបនៃអង្គព្រះយេស៊ូវ ដែលទ្រង់ជាតួអង្គមនុស្សផង ជាតួអង្គព្រះផង។

នៅពេលដែលក្សត្រដាវីឌសង់ទីក្រុងយេរូសាឡិមចប់សព្វគ្រប់ហើយ លោកមានចិត្តចង់នាំហិបសញ្ញារបស់ព្រះយកមកតម្កល់នៅក្នុងទីក្រុងនោះ។ ក្នុងខណៈដែលលោកកំពុងសង់ទីក្រុងយេរូសាឡិម ហិបសញ្ញានោះស្ថិតនៅភូមិគារយ៉ាត-យ៉ារីម ស្ថិតនៅប្រមាណជាដប់ពីរគីឡូម៉ែត្រ ខាងលិចទីក្រុងយេរូសាឡិម។ ស្តេចដាវីឌមានចិត្តស្រឡាញ់ដល់ព្រះជាម្ចាស់យ៉ាងខ្លាំង។ សព្វថ្ងៃ យើងពិបាកនឹងរកមនុស្សដែលស្រឡាញ់ដល់ព្រះជាម្ចាស់ដូចស្តេចដាវីឌណាស់។ ក្សត្រដាវីឌមានបុគ្គលិកលក្ខណៈល្អ ផ្សេងទៀតក្រៅពីកិរិយាដែលយើងតែងតែរិះគន់ដល់ទ្រង់។ បុគ្គលិកលក្ខណៈដែលល្អបំផុត គឺលោកមានចិត្តស្រឡាញ់ដល់ព្រះជាម្ចាស់។ ឯការស្រឡាញ់នោះផុសចេញពីក្នុងបេះដូងលោកតែម្តង។ នៅក្នុងគម្ពីរទំនុកដំកើង៩:១ លោកបញ្ជាក់សេចក្តីស្រឡាញ់ដែលផុសចេញពីក្នុងចិត្តលោកថា "ទូលបង្គំនឹងសរសើរដល់ព្រះយេហូវ៉ាអស់អំពីចិត្ត ទូលបង្គំនឹងនិទាន

ពីអស់ទាំងការអស្ចារ្យរបស់ទ្រង់”។ ម្យ៉ាងវិញទៀត លោកបញ្ជាក់ពីទឹកចិត្តរបស់លោកនៅក្នុងគម្ពីរទំនុកដំកើង១០៣:១ថា “ឱព្រលឹងអញអើយ ចូរសរសើរដល់ព្រះយេហូវ៉ា ហើយគ្រប់ទាំងអស់ដែលរួមនៅក្នុងខ្លួនអញ ចូរសរសើរដល់ព្រះនាមបរិសុទ្ធនៃទ្រង់ដែរ”។ ឯក្នុងគម្ពីរទំនុកដំកើង១០៨:១ លោកមានប្រសាសន៍ថា “ឱព្រះអង្គអើយ ចិត្តទូលបង្គំបានតាំងនៅមាំហើយ ទូលបង្គំនឹងច្រៀង អើ នឹងច្រៀងសរសើរ ដោយសារកិត្តិយសរបស់ទូលបង្គំដែរ”។ ក្សត្រដាវីឌមានចិត្តស្រឡាញ់ដល់ព្រះជាម្ចាស់ ព្រមទាំងចង់តម្កើងព្រះអង្គដោយផុសចេញពីក្នុងចិត្តរបស់លោកផ្ទាល់។ លោកមានចិត្តចង់នាំហិបសញ្ញារបស់ព្រះជាម្ចាស់ យកមកដាក់នៅទីក្រុងយេរូសាឡិម។ ចិត្តរបស់លោកចង់ធ្វើការល្អបំផុត តែមធ្យោបាយដែលលោកប្រើ ដើម្បីសម្រេចការនោះ គឺខុសនឹងច្បាប់របស់ព្រះ។ ដូច្នេះហើយ បានជាយើងអោយចំណងជើងជំពូក៦ថា “ក្សត្រដាវីឌធ្វើត្រូវក្នុងផ្លូវខុស”។

ជំពូក៦ បរិយាយអំពីហិបសញ្ញាចំនួនដប់ប្រាំដង គ្រាន់តែពីខមួយដល់ខដប់ប្រាំពីរ។ ដូច្នេះ ជំពូកនេះព្រះអង្គចង់បញ្ជាក់អោយយើងស្គាល់អំពីសារៈសំខាន់នៃហិបសញ្ញា។ ស្តេចដាវីឌមានចិត្តចង់នាំហិបសញ្ញារបស់ព្រះចូលមកក្នុងទីក្រុងយេរូសាឡិម ពីព្រោះលោកយល់ថា ហិបសញ្ញាមានសារៈសំខាន់សម្រាប់លោកណាស់។ ហិបសញ្ញាជានិមិត្តរូបនៃអង្គដែលនាំអោយមានការបង្រួបបង្រួមរវាងព្រះជាម្ចាស់ និងមនុស្សលោក។ សេចក្តីផ្តើមនៃមេរៀននេះវែង ប៉ុន្តែ ចាំបាច់ត្រូវពន្យល់អោយបានក្បោះក្បាយស្តីអំពីខ្លឹមសារនៃហិបសញ្ញា។ ឥឡូវ សូមយើងពិចារណាពីសកម្មភាពដែលស្តេច

ដាវីឌបាននាំហិបសញ្ញាចូលក្នុងទីក្រុងយេរូសាឡិម។

> **[១]រួចមកដាវីឌទ្រង់ប្រមូលអស់ទាំងមនុស្សជ្រើសរើស ក្នុងសាសន៍**
> **អីស្រាអែលម្តងទៀត បានចំនួន៣ម៉ឺននាក់ [២]រួចដាវីឌ ព្រមទាំង**
> **បណ្តាជនទាំងប៉ុន្មាន ក៏នាំគ្នាឡើងចេញពីបាលេ-យូដា ដើម្បីនឹង**
> **នាំយកហឹបនៃព្រះឡើងមក ជាហឹបដែលគេឱ្យឈ្មោះ តាមព្រះ**
> **នាមរបស់ព្រះយេហូវ៉ានៃពួកពលបរិវារ ដែលទ្រង់គង់នៅ**
> **កណ្តាលចេរូប៊ីន [៣]គេផ្ទុកហឹបនៃព្រះលើរទេះថ្មី ដឹកចេញពីផ្ទះអ័ប៊ី**
> **ន៉ាដាប់ ដែលនៅលើភ្នំទៅ មានឈ្មោះអ៊ុសា ហើយនឹងអ័ហ៊ីយ៉ូរ**
> **ជាកូនអ័ប៊ីន៉ាដាប់ ជាអ្នកបររទេះថ្មីនោះ (២សាំយូអែល៦:១-៣)។**

នៅក្នុងច្បាប់របស់ព្រះជាម្ចាស់ទ្រង់បង្គាប់ថា ហិបសញ្ញាត្រូវសែងដោយពួកសង្ឃលេវី។ ផ្ទុយទៅវិញ ស្តេចដាវីឌលើកយកហិបសញ្ញាទៅដាក់នៅលើរទេះ រួចហើយនាំគ្នាដង្ហែរចូលទីក្រុងយេរូសាឡិម។ ព្រះជាម្ចាស់មិនសព្វព្រះទ័យអោយស្តេចដាវីឌធ្វើយ៉ាងដូច្នោះទេ។ ស្តេចដាវីឌស្គាល់ព្រះជាម្ចាស់និងច្បាប់របស់ទ្រង់ លោកត្រូវតែទទួលខុសត្រូវនៅចំពោះព្រះភក្ត្រព្រះជាម្ចាស់ អំពីកំហុសរបស់លោក។ មនុស្សដទៃទៀត ដែលមិនស្គាល់ព្រះជាម្ចាស់ ដើរជំពប់ជាមួយនឹងច្បាប់របស់ព្រះជាម្ចាស់ តែមិនស្គាល់ច្បាប់របស់ទ្រង់ទេ។ ព្រះជាម្ចាស់អោយគេទទួលខុសត្រូវដែរ ដោយសារបាបដែល

គេមិនបានដឹង។ ប៉ុន្តែ អ្នកដែលដឹងហើយ ព្រះអង្គទាមទារអោយគេទទួលខុសត្រូវធ្ងន់ជាងអ្នកដែលមិនបានដឹង។ ព្រះបន្ទូលរបស់ព្រះបញ្ជាក់អំពីដំណើរនេះហើយ យើងត្រូវធ្វើតាមដោយគ្មានផ្លូវណាជ្រើសរើសផ្សេងទៀតទេ។

ការនាំហិបសញ្ញាចូលមកតម្កល់នៅក្នុងទីក្រុងយេរូសាឡិម នោះជាគំនិតយ៉ាងឧត្តុង្គឧត្តម។ ប៉ុន្តែ ក្សត្រដាវីឌមិនត្រូវដឹកហិបសញ្ញានៅក្នុងរទេះទេ គឺពួកសង្ឃលេវីត្រូវសែងវិញ។ ត្រង់ចំណុចនេះ ក្សត្រដាវីឌមិនបានស្ដាប់បង្គាប់តាមព្រះបន្ទូលរបស់ព្រះ។ លោកធ្វើត្រូវក្នុងផ្លូវខុស។

មេរៀនខាងលើបន្សល់ទុកនូវសេចក្ដីពិត សម្រាប់យើងយកមកអនុវត្ត។ ដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវប្រៀបឧបមាដូចជា ហិបសញ្ញារបស់ព្រះយ៉ាងដូច្នេះដែរ។ ព្រះអង្គទាមទារអោយយើងបញ្ជូនដំណឹងល្អទៅដល់មនុស្សលោក ដែលត្រូវការ។ ជួនកាលយើងគិតថា យើងមិនស័ក្តិសមនិងពាំនាំព្រះបន្ទូលរបស់ព្រះអង្គទៅហុចដល់អ្នកដទៃទេ។ យើងគិតយ៉ាងដូច្នេះ ព្រោះកិរិយាប្រព្រឹត្តរបស់យើងតែងតែធ្វើខុសទាស់ជាមួយនឹងព្រះអង្គ។ ព្រះអង្គគួរតែប្រើទេវតារបស់ទ្រង់ទើបត្រូវ ពីព្រោះដំណឹងល្អរបស់ព្រះអង្គមានភាពសុចរិតណាស់។ ប៉ុន្តែ អរគុណដល់ព្រះអម្ចាស់ ពីព្រោះទ្រង់ចាំបាច់ត្រូវប្រើស្មាយើង ដើម្បីលីព្រះបន្ទូលរបស់ព្រះអង្គ ទៅចែកចាយអោយដល់អ្នកដទៃ។ ស្ដេចដាវីឌធ្វើខុសមែន តែចិត្តរបស់លោកចង់ថ្វាយសិរីល្អដល់ព្រះជាម្ចាស់។ ដោយសារលោកធ្វើត្រូវក្នុងផ្លូវខុស លោកជួបជាមួយនឹងបញ្ហាជាប្រាកដ។ យើងជារាស្ត្ររបស់ព្រះអង្គ តែងធ្វើខុសដូចក្សត្រដាវីឌ។ ព្រះជាម្ចាស់ចាំបាច់ត្រូវជួយតម្រែតម្រង់យើង

ដើម្បីអោយយើងធ្វើត្រូវតាមផ្លូវរបស់ទ្រង់។

> **ឯដាវីឌ នឹងពួកផ្ទះអ៊ីស្រាអែលទាំងអស់ គេលេងប្រដាប់ភ្លេងគ្រប់មុខ ដែលធ្វើពីឈើកកោះ គឺស៊ុង ពិណ ក្រាប់ រុម្មនា ហើយនឹងឈឹង នៅចំពោះព្រះយេហូវ៉ា (២សាំយូអែល៦:៥)។**

ក្សត្រដាវីឌជាតន្ត្រីករយ៉ាងចំណាន។ លោកជឿថា ដើម្បីដង្ហែរហិបសញ្ញារបស់ព្រះជាម្ចាស់ចូលទៅទីក្រុងយេរូសាឡិម លោកចាំបាច់ត្រូវមានគ្រឿងភ្លេងជាច្រើន ដើម្បីប្រគំអោយពីរោះយ៉ាងអធិកអធម។

> **៦ លុះគេបានទៅដល់លានស្រូវរបស់ណាកុនហើយ នោះអ៊ុសាគាត់លូកដៃទៅចាប់ទប់ហឹបនៃព្រះ ពីព្រោះគោកព្រៀលឡើង**
> **៧ ដូច្នេះ ព្រះយេហូវ៉ាទ្រង់ខ្ញាល់នឹងអ៊ុសា ក៏ប្រហារគាត់នៅទីនោះ ដោយព្រោះកំហុសរបស់គាត់ ហើយគាត់ស្លាប់នៅទីនោះ ជិតហឹបនៃព្រះទៅ (២សាំយូអែល៦:៦-៧)។**

ឥឡូវ យើងឃើញព្រះជាម្ចាស់មិនសព្វព្រះទ័យជាមួយនឹងផ្លូវប្រព្រឹត្តខុសរបស់ស្តេចដាវីឌទេ។ នៅពេលដាក់ហិបសញ្ញារបស់ព្រះនៅលើរទេះ គោក៏កព្រៀលឡើង។

លុះឃើញហិបសញ្ញារបស់ព្រះហៀបនឹងធ្លាក់ អ៊ុសាលូកដៃទៅទប់អោយហិបសញ្ញានោះនៅស្ងៀម។ ព្រះជាម្ចាស់ក៏ប្រហារលោកអ៊ុសាចោលទៅ ដោយបានប៉ះហិបសញ្ញារបស់ទ្រង់។ ផែនការរបស់ស្តេចដាវីឌ ក្នុងការនាំហិបសញ្ញារបស់ព្រះចូលទីក្រុងយេរូសាឡិម ត្រូវបរាជ័យនៅក្នុងពេលនេះ។ ក្សត្រដាវីឌមានសេចក្តីអាក់អន់ស្រពន់ចិត្តជាមួយនឹងព្រះជាម្ចាស់ ឯព្រះជាម្ចាស់ក៏សម្តែងព្រះទ័យខឹងសម្បារជាមួយនឹងស្តេចដាវីឌដែរ។ ព្រះជាម្ចាស់មិនសព្វព្រះទ័យអោយស្តេចដាវីឌដឹកហិបសញ្ញានៅលើរទេះទេ។ មធ្យោបាយនេះ គឺជាមធ្យោបាយខុស ព្រះជាម្ចាស់មិនអនុញ្ញាតអោយប្រើប្រាស់របៀបនេះឡើយ។

> **៨ ឯដាវីឌទ្រង់មានព្រះទ័យទោមនស្ស ដោយព្រោះព្រះយេហូវ៉ា**
> **បានប្រហារជីវិតអ៊ុសាបង់ រួចទ្រង់ហៅកន្លែងនោះឈ្មោះថា**
> **ពេរេស-អ៊ុសា ដរាបដល់សព្វថ្ងៃនេះ ៩ នៅថ្ងៃនោះដាវីឌក៏មាន**
> **សេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា ហើយមានបន្ទូលថា ធ្វើដូចម្តេចឱ្យហឹបនៃព្រះយេហូវ៉ាចូលមកឯអញបាន (២សាំយូអែល៦:៨-៩)។**

យើងអាចយកសេចក្តីពិតក្នុងអត្ថបទខាងលើ មកអនុវត្តនៅក្នុងជីវិតរបស់យើង។ ថ្វីដ្បិតក្សត្រដាវីឌប្រើវិធីខុសក្នុងការបម្រើព្រះជាម្ចាស់មែន លោកមានចិត្តកោត

ខ្លាចដល់ទ្រង់ណាស់។ សេចក្ដីកោតខ្លាច ជាដើមចមនៃប្រាជ្ញា (សូមអានគម្ពីរទំនុកដំកើង១១១:១០)។ សព្វថ្ងៃមនុស្សលោកត្រូវទទួលស្គាល់ហេតុការណ៍នេះ។ ព្រះជាម្ចាស់ពិតជាព្រះដែលស្រឡាញ់ដល់មនុស្សលោកមែន តែទ្រង់ជាព្រះដែលជំនុំជំរះអំពើបាបរបស់មនុស្សលោកផងដែរ។ យើងចាំបាច់ត្រូវចូលទៅឯព្រះអង្គតាមផ្លូវដែលទ្រង់រៀបទុកសម្រាប់យើង។ បើយើងធ្វើខុសនឹងព្រះបន្ទូលទ្រង់ យើងត្រូវត្រៀមខ្លួនទទួលការជំនុំជំរះពីព្រះអង្គ។ ព្រះយេស៊ូវសម្ដែងក្នុងគម្ពីរយ៉ូហាន១៤:៦ថា "...ខ្ញុំជាផ្លូវ ជាសេចក្ដីពិត ហើយជាជីវិត បើមិនមកតាមខ្ញុំនោះ គ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ"។ ព្រះយេស៊ូវមានបន្ទូលពីពាក្យទាំងនេះ ហើយពាក្យទាំងនេះសុទ្ធតែត្រឹមត្រូវ។ យើងត្រូវកោតខ្លាចដល់ព្រះបន្ទូលរបស់ព្រះ ដែលទ្រង់មានបន្ទូលមកកាន់យើង។ ស្ដេចដាវីឌមានសេចក្ដីកោតខ្លាចដល់ព្រះជាម្ចាស់ បានជាលោកសួរថា "តើខ្ញុំត្រូវធ្វើយ៉ាងដូចម្ដេច ដើម្បីនាំហិបសញ្ញារបស់ព្រះជាម្ចាស់ចូលទៅក្នុងទីក្រុងបាន?"

> **[១០]យ៉ាងនោះ ដាវីឌបែរជាមិនបាននាំយកហឹបនៃព្រះយេហូវ៉ា ចូលទៅឯទ្រង់ ក្នុងក្រុងរបស់ទ្រង់ទេ គឺទ្រង់នាំយកទៅដាក់ទុកនៅក្នុងផ្ទះរបស់អូបិឌ-អេដំម ជាអ្នកមកពីក្រុងកាថវិញ [១១]ដូច្នេះ ហឹបនៃព្រះយេហូវ៉ាក៏នៅក្នុងផ្ទះរបស់អូបិឌ-អេដំម ពីក្រុងកាថនោះអស់៣ខែ ហើយព្រះយេហូវ៉ាក៏ប្រទានពរដល់អូបិឌ-អេដំម ព្រមទាំងពួកគ្រួគាត់ទាំងអស់គ្នា [១២]មានគេក្រាបទូលដល់ស្ដេច**

**ដាវីឌថា ព្រះយេហូវ៉ាបានប្រទានពរដល់ពួកគ្រួអូបិឌ-អេដំម នឹងរបស់គាត់ទាំងអស់ ដោយព្រោះហឹបនៃព្រះ ដូច្នេះ ដាវីឌទ្រង់ក៏យាងទៅនាំយកហឹបនៃព្រះ ពីផ្ទះអូបិឌ-អេដំម ចូលមកក្នុងក្រុងរបស់ទ្រង់វិញដោយអំណរ (២សាំយូអែល៦:១០-១២)។**

ស្តេចដាវីឌមានទឹកចិត្តប្តូរផ្តាច់ ព្រមផ្លាស់ប្តូរយុទ្ធវិធី ដើម្បីនាំហិបសញ្ញារបស់ព្រះចូលអោយដល់ទីក្រុងរបស់លោក។ លោករៀនពីមេរៀនដែលលោកធ្វើខុស។ លោកត្រូវនាំហិបសញ្ញាចូលទៅក្នុងទីក្រុង ដោយអោយពួកសង្ឃសែងតាមច្បាប់របស់ព្រះជាម្ចាស់វិញ។

**១៣ កាលពួកអ្នកដែលសែងហឹបនៃព្រះយេហូវ៉ា ដើរទៅបាន៦ជំហាន នោះទ្រង់ថ្វាយគោឈ្មោល១ នឹងកូនគោ១យ៉ាងធាត់
១៤ ដាវីឌក៏លោតកញ្ឆេងអស់ពីកំឡាំងទ្រង់ នៅចំពោះព្រះយេហូវ៉ា ទ្រង់ពាក់អេផូឌធ្វើពីសំពត់ខ្លូតទេស (២សាំយូអែល៦:១៣-១៤)។**

បើលោកអ្នកបងប្អូនមិនដែលឮថា គ្រីស្ទបរិស័ទអាចរាំថ្វាយបង្គំព្រះបាន លោកអ្នកប្រហែលជាជ្រួញចិញ្ចើមហើយ បន្ទាប់ពីអានខគម្ពីរនេះ។ កិរិយាដែលដាវីឌរាំថ្វាយបង្គំព្រះ មានកត់ទុកនៅក្នុងព្រះបន្ទូលរបស់ទ្រង់។ ក្សត្រដាវីឌរាំ ដើម្បីថ្វាយបង្គំ

ដល់ព្រះជាម្ចាស់។ ការរាំរែកសព្វថ្ងៃនេះ ធ្វើឡើងសម្រាប់បម្រើការស្រើបស្រាលដែលនាំអោយធ្លាក់ខ្លួនទៅក្នុងកាមគុណតែប៉ុណ្ណោះ។ ខ្ញុំយល់ថា ការរាំរែកសព្វថ្ងៃនេះ ទោះបីជារាំរបៀបណាក្តី សុទ្ធតែជាការរាំរែកបម្រើកាមគុណ។ ចំណែកស្តេចដាវីឌលោករាំថ្វាយបង្គំព្រះ គឺមិនមែនសម្រាប់បម្រើកាមគុណឡើយ។ បើលោកអ្នកកាន់ចិត្តរាំថ្វាយបង្គំព្រះបាន សូមលោកអ្នករាំថ្វាយបង្គំព្រះអង្គចុះ។ ប៉ុន្តែ ខ្ញុំសូមទូន្មានដល់លោកអ្នកដែលចង់រាំថ្វាយព្រះអោយប្រយ័ត្ននឹងចិត្តភ្លើតភ្លើនរបស់លោកអ្នក។ បើលោកអ្នករាំថ្វាយព្រះ ដោយសម្លឹងមើលរាងរបស់បុរស ឬស្ត្រី ហើយគិតថា រាងអ្នកនេះរាងនាងនោះរាំសមណាស់។ លោកអ្នកប្រហែលជាមានចិត្តគិតពីកាមគុណ ក្នុងទ្រង់ទ្រាយចាំថ្វាយបង្គំដល់ព្រះជាម្ចាស់។ បើលោកអ្នកមានគំនិតយ៉ាងដូច្នេះមែន ការរាំថ្វាយបង្គំព្រះរបស់លោកអ្នក ច្បាស់ជាធ្វើបាបទាស់នឹងព្រះអង្គជាប្រាកដ។ ខ្ញុំធ្លាប់ឮគេនិយាយថា គ្រីស្ទបរិស័ទចាក់ភ្លេងនាំគ្នារាំដើម្បីថ្វាយបង្គំព្រះទល់ពាក់កណ្តាលអធ្រាត្រ។ ខ្ញុំយល់ថា រឿងនេះ គ្រីស្ទបរិស័ទកំពុងរាំរែកបម្រើកាមគុណហើយ គឺមិនមែនថ្វាយបង្គំព្រះជាម្ចាស់ទេ។ យើងពិបាកវិនិច្ឆ័យថា តើរាំបែបណាជាការរាំថ្វាយបង្គំព្រះ រាំបែបណាជាការរាំបម្រើកាមគុណ។ ចំណែកខ្ញុំ ខ្ញុំយល់ដឹងខ្លួនឯង ពេលខ្ញុំរាំថ្វាយព្រះ គឺខ្ញុំអាចរាំដោយចិត្តរបស់ខ្ញុំរីករាយសាទរជាមួយនឹងព្រះជាម្ចាស់ជាអង្គសង្គ្រោះរបស់ខ្ញុំ។ ខ្ញុំយល់ថា ការរាំប្រមាណប្រាំទៅដប់នាទី ដោយច្រៀងមួយឬពីរបទ ជាបទចម្រៀងថ្វាយបង្គំព្រះ នោះសមរម្យល្មមហើយ។ ទ្រឹស្តីនេះ មិនមែនល្អបណ្តាច់ទេ គឺប្រាកដជាមានអ្នកខ្លះរិះគន់គំនិតរបស់ខ្ញុំជាមិនខាន។ ខ្ញុំធ្វើការសន្និដ្ឋានបែបនេះ ដោយមានការប្រាកដនៅ

ក្នុងចិត្តខ្ញុំ។ គ្រីស្ទបរិស័ទមិនត្រូវធ្វើមុខជូររហូតទេ គឺយើងត្រូវមានចិត្តរីករាយសប្បាយដែរ។ ឯការសប្បាយរបស់យើងត្រូវបញ្ចេញក្នុងការរាំថ្វាយព្រះក៏បាន នៅស្ងាត់ស្ងៀមថ្វាយបង្គំព្រះក៏បាន។ ស្តេចដាវីឌសម្តែងសេចក្តីសប្បាយរីករាយរបស់ទ្រង់ដោយរាំថ្វាយបង្គំព្រះជាម្ចាស់។

> **១៥ ដូច្នេះ ដាវីឌនឹងជំនួរវង្សនៃសាសន៍អ៊ីស្រាអែលទាំងអស់ បាន**
> **នាំហឹបនៃព្រះយេហូវ៉ាឡើងមកដោយសំឡេងហ៊ោឡើង នឹងសូរ**
> **ផ្លុំត្រែផង ១៦ ក្នុងវេលាដែលហឹបនៃព្រះយេហូវ៉ា កំពុងតែចូលមក**
> **ក្នុងក្រុងដាវីឌ នោះមីកាលជាបុត្រីសូល ក៏ទតតាមបង្អួចទៅ**
> **ឃើញស្តេចដាវីឌ កំពុងតែហក់លោតកញ្ឆេងនៅចំពោះព្រះយេ**
> **ហូវ៉ា នាងក៏មានព្រះទ័យប្រមាថមើលងាយដល់ទ្រង់ (២សាំយូ**
> **អែល៦:១៥-១៦)។**

នាងមីកាលដែលជាជាយារបស់ក្សត្រដាវីឌ មិនសប្បាយចិត្តជាមួយនឹងស្វាមីរបស់នាងស្រឡាញ់ដល់ព្រះជាម្ចាស់យ៉ាងដូច្នេះទេ។ នាងពោលពាក្យមើលងាយមើលថោកដល់ស្តេចដាវីឌដោយលោកសប្បាយជាមួយនឹងព្រះជាម្ចាស់របស់លោក។

**គេនាំយកហឹបនៃព្រះយេហូវ៉ាចូលមកដាក់នៅកន្លែងរៀបចំ ត្រង់**

**កណ្ដាលត្រសាល ដែលដាវីឌបានដំឡើងសំរាប់ហឹបនោះ រួចទ្រង់ថ្វាយដង្វាយដុត នឹងដង្វាយមេត្រី នៅចំពោះព្រះយេហូវ៉ា (២សាំយូអែល៦:១៧)។**

ដង្វាយដុតខាងលើសម្ដែងអំពីអង្គព្រះយេស៊ូវគ្រីស្ទ។ ដង្វាយមេត្រីសម្ដែងអំពីព្រះយេស៊ូវដែលទ្រង់សុគតនៅលើឈើឆ្កាង។ ទ្រង់សុគតដើម្បីនាំសេចក្ដីមេត្រីរវាងព្រះ ហើយនិងមនុស្ស។ ស្ដេចដាវីឌថ្វាយដង្វាយមេត្រី ដើម្បីបញ្ជាក់ថា លោកហើយនិងព្រះជាម្ចាស់បានជានានឹងគ្នា។

**រួចហើយ ដាវីឌទ្រង់យាងត្រឡប់ទៅឯដំណាក់ ដើម្បីឱ្យពរដល់ពួកដំណាក់ទ្រង់ នោះមីកាលជាបុត្រីសូល នាងចេញមកទទួលទ្រង់ ទូលថា នៅថ្ងៃនេះ ស្ដេចនៃសាសន៍អ៊ីស្រាអែល មានសេចក្ដីរុងរឿងឧត្តមអីម្ល៉េះទេ ដោយបានបើកឱ្យអង្គទ្រង់អាក្រាតនៅមុខពួកស្រីបំរើរបស់ពួកមហាតលិកទ្រង់នៅថ្ងៃនេះ បែបដូចជាមនុស្សចោលម្សៀតណាមួយដែលបើកឱ្យខ្លួនអាក្រាតដូច្នេះ (២សាំយូអែល៦:២០)។**

គម្ពីរនេះបានចែងថា ក្សត្រដាវីឌរាំរហូតដល់ "...បើកឱ្យខ្លួនអាក្រាត..."។

តើស្តេចដាវីឌរាំទាល់តែរបូតខោរបូតអាវមែនឬ? បើតាមខ្ញុំយល់ ស្តេចដាវីឌមិនមែនរាំរហូតទៅដល់របូតខោរបូតអាវ ដូចនាងមីកាលនិយាយនោះទេ។ លោកគ្រាន់តែដោះព្រះពស្ត្រជាស្តេចដាក់មួយកន្លែង ហើយលោកស្លៀកតែខោអាវក្នុង ពេលទ្រង់រាំថ្វាយបង្គំព្រះជាម្ចាស់។ នាងមីកាលមិនមែនស្រឡាញ់បុគ្គលដាវីឌទេ គឺនាងស្រឡាញ់គ្រឿងព្រះពស្ត្ររបស់ស្តេចដាវីឌវិញ។ នាងមីកាលជារូបភាពនៃជនដែលកាន់សាសនាគ្រីស្ទយ៉ាងមុតមាំ។ នាងមិនចង់ឃើញស្តេចដាវីឌសម្តែងទំនាក់ទំនងរបស់លោកជាមួយនឹងព្រះអង្គសង្គ្រោះរបស់ទ្រង់ដោយរីករាយទេ។ នាងមីកាលចូលចិត្តសម្តែងបែបសាសនាដែលសំបកក្រៅមើលទៅ ថាជាអ្នកដែលរម្យទម។ យើងត្រូវប្រយ័ត្នជាមួយនឹងមនុស្សប្រភេទនោះ។ មានគ្រីស្ទបរិស័ទខ្លះរម្យទម អឹមអៀម តែបើនិយាយពីក្លិនវិញ ក្រអូបស្មើនឹងលាមកក្រៀមត្រូវទឹក។ មនុស្សប្រភេទនេះ មានពិលពុលណាស់។ ចំណែកស្តេចដាវីឌ លោកកោតខ្លាចដល់ព្រះ បានជាលោកមានសេចក្តីរីករាយសម្តែងការកោតខ្លាចដល់ព្រះ អោយមនុស្សដទៃទៀតឃើញ។ ស្តេចដាវីឌពិតជាអ្នកសំណព្វរបស់ព្រះមែន។

> **តែដាវីឌមានបន្ទូលតបថា នោះគឺនៅចំពោះព្រះយេហូវ៉ាទេ ជាព្រះដែលបានរើសអញជាជាងបិតាឯង នឹងវង្សានុវង្សរបស់ឯងទាំងអស់គ្នាដែរ ដើម្បីនឹងតាំងអញឡើងជាស្តេចលើសាសន៍អីស្រាអែល ជារាស្ត្ររបស់ព្រះយេហូវ៉ា ហេតុដូច្នេះបានជាអញ**

**នឹងលេងសប្បាយ នៅចំពោះព្រះយេហូវ៉ា (២សាំយូអែល៦:២១)។**

ក្សត្រដាវីឌឆ្លើយតបជាមួយនឹងនាងមីកាល "...គឺនៅចំពោះព្រះយេហូវ៉ាទេ ជាព្រះដែលបានរើសអញជាជាងបិតាឯង នឹងវង្សានុវង្សរបស់ឯងទាំងអស់គ្នាដែរ ដើម្បីនឹងតាំងអញឡើងជាស្តេចលើសាសន៍អ៊ីស្រាអែល ជារាស្ត្ររបស់ព្រះយេហូវ៉ា ហេតុដូច្នេះបានជាអញនឹងលេងសប្បាយនៅចំពោះព្រះយេហូវ៉ា"។ លោកអ្នកបងប្អូនអើយ ខ្ញុំចង់ឃើញលោកអ្នកដែលនិយាយថា ស្រឡាញ់ដល់ព្រះអម្ចាស់យេស៊ូវ សម្តែងសេចក្តីរីករាយដូចក្សត្រដាវីឌ សម្តែងសេចក្តីត្រេកអរនៅចំពោះព្រះជាម្ចាស់។ ខ្ញុំចង់ឃើញវិហារនីមួយៗមានការថ្វាយបង្គំដោយរីករាយ អរសប្បាយពេញដោយព្រះចេស្តារបស់ទ្រង់។ លោកអ្នកបានឃើញកិរិយាប្រព្រឹត្តដែលស្តេចដាវីឌបានរាំសប្បាយនៅចំពោះមុខលោកអ្នកហើយ។ ខ្ញុំចង់អោយលោកអ្នកបងប្អូនមានសេចក្តីរីករាយក្នុងការថ្វាយបង្គំព្រះ ពេលចូលមកថ្វាយបង្គំព្រះអង្គរៀងរាល់ថ្ងៃបរិសុទ្ធ។

**ហើយនឹងចេះតែប្រព្រឹត្តអាក្រក់ជាងនោះទៅទៀត ព្រមទាំងបានទាបថោកដល់ភ្នែកខ្លួនអញផង តែចំណែកពួកបាវស្រីដែលឯងបាននិយាយនោះ គេនឹងលើកសរសើរដល់អញវិញ (២សាំយូអែល៦:២២)។**

ស្តេចដាវីឌមានបន្ទូលថា “ហើយនឹងចេះតែប្រព្រឹត្តអាក្រក់ជាងនោះទៅទៀត ព្រមទាំងបានទាបថោកដល់ភ្នែកខ្លួនអញផង...”។ តើឃ្លានេះមានន័យយ៉ាងដូចម្តេច ទាក់ទងជាមួយនឹងការថ្វាយបង្គំដល់ព្រះជាម្ចាស់? ចំពោះភ្នែករបស់នាងមីកាល ការថ្វាយបង្គំដោយមានចិត្តរីករាយអបអរសាទរដូចស្តេចដាវីឌ រាប់ថាជាអំពើអាក្រក់។ ក្សត្រដាវីឌឆ្លើយថា បើនាងយល់ថា ការថ្វាយបង្គំព្រះតាមរបៀបនេះ ជាការអាក្រក់ លោកនឹងថ្វាយបង្គំព្រះអោយនាងមីកាលថា រឹតតែអាក្រក់ជាងនោះទៅទៀត។ លោកចង់បញ្ជាក់ប្រាប់ជាយារបស់លោកថា លោកនឹងថ្វាយបង្គំដល់ព្រះរហូតដល់អ្នកដទៃទៀត គេនិយាយថា ទ្រង់ជាអ្នកថោកទាបដោយថ្វាយបង្គំដល់ព្រះជាម្ចាស់ជាព្រះដ៏រស់។ ស្តេចដាវីឌមិនខ្វល់ថា អ្នកណានិយាយអាក្រក់ពីលោកទេ អោយតែលោកបានថ្វាយបង្គំដល់ព្រះជាម្ចាស់របស់លោកដោយចិត្តស្មោះស។ តើយើងមានអត្តចរិតដូចក្សត្រដាវីឌដែរឬទេ? មនុស្សដទៃទៀតយល់ថា យើងជាមនុស្សថោកទាប ពីព្រោះទៅថ្វាយបង្គំដល់ព្រះអម្ចាស់យេស៊ូវ ជាព្រះដែលសុគតនៅលើឈើឆ្កាង។ លោកអ្នកបងប្អូនអើយ ព្រះយេស៊ូវសុគតនៅលើឈើឆ្កាង មិនមែនជំនួសទោសរបស់ទ្រង់ទេ។ ទ្រង់សុគតនៅលើឈើឆ្កាងដើម្បីជំនួសទោសរបស់យើងគ្រប់គ្នា។ ព្រះអង្គមិនមែនសុគតរហូត តែបីថ្ងៃក្រោយមកព្រះអង្គរស់ឡើងវិញ ដើម្បីផ្ទេរសេចក្តីសុចរិតមកអោយយើងរាល់គ្នា។ តើបេសកកម្មដ៏ខ្ពស់បំផុតរបស់ព្រះយេស៊ូវ ដែលយាងចុះពីស្ថានសួគ៌មកសុគតជំនួសយើងនៅលើឈើឆ្កាង ព្រមទាំងរស់ឡើងវិញដើម្បីផ្តល់អោយយើងមានសេចក្តីសុចរិតនៅចំពោះព្រះ ជារឿងថោកទាបឬ? យើងមិនយល់ថា ការដែលព្រះ

អម្ចាស់យេស៊ូវធ្វើសម្រាប់យើង ជារឿងថោកទាបទេ។ ដូច្នេះ យើងត្រូវថ្វាយបង្គំដល់ព្រះយេស៊ូវគ្រីស្ទ អោយអស់ពីចិត្តអស់ពីគំនិត និងអស់ពីព្រលឹងរបស់យើង ទោះបីអ្នកផងទាំងពួងយល់ថា យើងជាមនុស្សថោកទាបយ៉ាងណាក៏ដោយ។ គេថាយើងថោកចុះ កុំអោយតែយើងធ្វើថោកមែន។ ការថ្វាយបង្គំដល់ព្រះជាម្ចាស់ ដោយរីករាយអរសប្បាយ មិនមែនរាប់ថាជាអំពើថោកទាបទេ។

នាងមីកាលជាជាយារបស់ក្សត្រដាវីឌ មើលងាយដល់ស្តេចដាវីឌដោយទ្រង់ថ្វាយបង្គំព្រះដោយរីករាយផុសចេញក្នុងចិត្តរបស់លោក។ ដោយសារមូលហេតុនោះបានជាស្តេចដាវីឌដាក់ទោសដល់នាងមីកាល ជាបុត្រីសូល មិនអោយនាងមានកូនអស់មួយជីវិត។ នាងមីកាលត្រូវរងទុក្ខដោយប្រការនោះ ដោយបានមើលងាយដល់ស្តេចដាវីឌ ដែលថ្វាយបង្គំព្រះដោយរីករាយ។ នាងមីកាលមិនមានកូនណាមួយតាមរយៈក្សត្រដាវីឌដែលស្រឡាញ់ដល់ព្រះជាម្ចាស់ ព្រមទាំងមានចិត្តឧស្សាហ៍ដល់កិច្ចការងាររបស់ព្រះដ៏ខ្ពស់បំផុតទេ។

យើងស្លេះការសិក្សាគម្ពីរ២សាំយូអែលត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"